# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបោះជំរំជំទង់នៅចំការទៀង
# ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨
*ជីវិតជាការតស៊ូឆ្លងទុក្ខលំបាកដើម្បីរកពន្លឺ*

អត្ថបទទី១៖ យរ ៣១,៧-៩
អត្ថបទទី២៖ ហាប ៥,១-៦
ដំណឹងល្អ៖ មក ១០,៤៦-៥២

បងប្អូនជាទីស្រឡាញ់!

យប់មិញអស្ចារ្យ ដោយសារយប់មិញយើងបានសម្តែងទេពកោសល្យពីធម្មជាតិ ទាំងក្រុមសិល្បៈចម្ការទៀង និងក្រុមផ្សេងៗ ដែលបានបង្ហាញទេពកោសល្យពីធម្មជាតិ។ នេះជាអ្វីដែលយើងបានគិតប៉ុន្មានថ្ងៃកន្លងមក សិល្បៈ និងទេពកោសល្យពីធម្មជាតិ។ យើងបានឃើញក្រុមនីមួយៗបានបង្ហាញអ្វីដែលប្លែកៗ ប៉ុន្តែជាពិសេសបានបង្ហាញអស់ពីចិត្ត។ ទោះបីរៀនភ្លេងបុរាណតែមួយថ្ងៃ ទោះបីកែច្នៃមកបានតែមួយថ្ងៃ រៀនគូររូបតែមួយថ្ងៃ បានចេញស្នាដៃដ៏អស្ចារ្យ។ ស្នាដៃដ៏អស្ចារ្យនេះ បានមកពីចិត្តនិងខ្លួនរបស់យើង ដោយសារយើងបានខិតខំយកចិត្តទុកដាក់ ធ្វើអស់ពីសមត្ថភាព នេះយើងមានក្តីសង្ឃឹមសម្រាប់អនាគត ដោយសារចាប់ពីពេលនេះតទៅខ្ញុំអាចយល់ ខ្ញុំមានសមត្ថភាពអ្វីខ្លះ?

ក្នុងគម្ពីរដំណឹងល្អ គឺរឿងអ្នកខ្វាក់មើលមិនឃើញ តែគាត់ស្តាប់ឮថាព្រះយេស៊ូកំពុងធ្វើដំណើរនៅជិតគាត់ ហើយគាត់ចាប់ផ្តើមស្រែកយ៉ាងខ្លាំង «**ឱព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមមេត្តាអាណិតទូលបង្គំផង!**»។ អាណិតមេត្តាដោយសារគាត់មើលមិនឃើញ ដោយសារគាត់ពិបាកធ្វើអ្វីមិនបាន។ អាទិត្យមុន ខ្ញុំទៅញ៉ាំនៅភោជនីដ្ឋានមួយពិសេសនៅភ្នំពេញ ដែលគេបិទភ្លើងទាំងអស់ ព្រោះមានអ្នកបម្រើតុដោយមនុស្សពិការភ្នែក ហើយគេចង់ឲ្យយើងដែលមើលឃើញមានបទពិសោធដូចគេ។ ដូច្នេះភោជនីដ្ឋាននេះ អត់មានបង្អួច អត់មានភ្លើង អត់មានអីសោះ គេចាប់ដៃយើងដើម្បីចូលក្នុងបន្ទប់ ហើយពេលយើងអង្គុយនៅក្នុងភាពងងឹតមែនទែន។ មនុស្សពិការភ្នែក គេពូកែដោយសារគេរស់នៅក្នុងភាពងងឹតហើយ ដូច្នេះគេដឹង គេស្គាល់តុនៅកន្លែងណា កៅអីនៅកន្លែងណា ម្ហូបគេដាក់នៅកន្លែងណា ហើយយើងដែលធ្លាប់រស់នៅក្នុងពន្លឺមើលមិនឃើញអ្វីសោះពិបាកណាស់។ ពេលនោះ យើងយល់ យើងមានសំណាងណាស់ដោយសារយើងមើលឃើញ។

ដូច្នេះ មនុស្សពិការភ្នែកនេះគាត់ចង់មើលឃើញដូចគេដូចឯង ប៉ុន្តែគាត់មិនហ៊ានសុំអីទេ គាត់ទទួលស្គាល់ថា គាត់ជាមនុស្សដែលពិបាក និងសុំក្តីអាណិតមេត្តា ព្រះយេស៊ូស្តាប់ឮ

ដោយសារព្រះអង្គចាប់អារម្មណ៍។ ថ្ងៃនោះមានមនុស្សច្រើនណាស់ដែលកំពុងហៅព្រះយេស៊ូ ហើយព្រះយេស៊ូបានចាប់អារម្មណ៍ រួចមានព្រះបន្ទូលថា "**សូមហៅគាត់មក**" គេហៅមនុស្សខ្វាក់ ដោយពោលថា «**កុំអស់សង្ឃឹម ក្រោកឡើង លោកហៅអ្នក**»។ ពេលនោះគាត់កំពុងអង្គុយសុំទាន គាត់បោះអាវធំចោល ស្ទុះក្រោកឡើង តម្រង់ទៅរកព្រះយេស៊ូ។ មានន័យថា គាត់ឈរឡើងលឿនណាស់ លោតដូចពពៃ ហើយនេះបង្ហាញថាទោះបីគាត់មនុស្សខ្វាក់ គាត់យល់ថាឥឡូវនេះ គាត់មានក្ដីសង្ឃឹម ដោយសារព្រះយេស៊ូចាប់អារម្មណ៍អំពីគាត់ និងដោយសារព្រះយេស៊ូបានលើកទឹកចិត្តគាត់ ដូច្នេះអត់ដឹងអ្វីដែលនឹងកើតឡើង។ គាត់ចង់មានទំនាក់ទំនងពិសេសជាមួយព្រះយេស៊ូ ហើយនៅពេលនោះ ព្រះយេស៊ូជួយគាត់ ដើម្បីឲ្យគាត់និយាយអំពីគោលបំណងរបស់គាត់។ ព្រះអង្គសួរថា «**តើអ្នកចង់ឲ្យខ្ញុំធ្វើអ្វី?**» តាមពិតព្រះអង្គឈ្វេងយល់គំនិតរបស់គាត់ហើយ។ ក្រោយមកគាត់ឆ្លើយច្បាស់ «**សូមប្រោសភ្នែកទូលបង្គំឲ្យបានភ្លឺផង**» ហើយនៅពេលព្រះយេស៊ូបានឃើញនូវគោលបំណង ចេញពីចិត្តគំនិតរបស់គាត់ពិតៗ ព្រះអង្គណែនាំឲ្យគាត់បានជាសះស្បើយ។

សម្រាប់យើងក៏ដូច្នេះដែរ នៅពេលព្រះយេស៊ូឃើញ យើងយកចិត្តទុកដាក់ ខិតខំ ព្រះអង្គជំរុញថែមទៀត ដើម្បីទៅជាមនុស្សដ៏ពេញលក្ខណៈ។ រាល់ឆ្នាំនៅសាលាមត្តេយ្យយើង ពេលបិទឆ្នាំសិក្សា យើងសួរដល់កូនម្នាក់ៗ **តើអនាគតចង់ធ្វើអ្វី?** គេឆ្លើយប្រហែលដោយនឹកឃើញបងៗ ឬឪពុកម្ដាយ និងតាមអ្វីដែលគេឃើញតាមទូរទស្សន៍ រាល់ឆ្នាំខ្ញុំលឺថា គេចង់ធ្វើប៉ូលីស លោកគ្រូ អ្នកគ្រូ ជួនកាលមេធាវី ចង់ធ្វើការងារនៅការិយាល័យ។ អ្វីដែលសំខាន់ គេមានគោលបំណងដូចលោកបាទីមេ (មនុស្សខ្វាក់)នោះ។

យប់មិញ យើងបានសម្ដែងទេពកោសល្យរបស់យើង ដើម្បីបង្ហាញថាយើងជាមនុស្សដែលមានសមត្ថភាពណាស់ ហេតុនេះហើយយើងត្រូវគិតពិចារណានៅក្នុងជីវិតរបស់យើង ជាពិសេសសម្រាប់និស្សិតដែលចូលឆ្នាំទី១ កុំគិតថា ទេពកោសល្យចេញពីធម្មជាតិរបស់ខ្ញុំ គឺសម្រាប់កូនក្មេងតែប៉ុណ្ណឹង គឺត្រូវនឹកឃើញអនាគត **តើខ្ញុំត្រូវការធ្វើជាមនុស្សយ៉ាងម៉េច? ខ្ញុំត្រូវការបម្រើសង្គមដូចម្ដេច? ខ្ញុំត្រូវចូលរួមក្នុងការកសាងប្រទេស និងសង្គមគ្រួសាររបៀបណា?** កុំឲ្យយើងធ្វើប្រហែលៗ ដោយគិតថាពេលនេះយើងមានម្ហូបអាហារ យើងមានកន្លែងដេក មានទឹកភ្លើង មានការសិក្សាឥតបង់ថ្លៃ យើងមានកុំព្យូទ័រ...។ កុំគិតខុស! ជីវិតជាការតស៊ូឆ្លងទុក្ខលំបាក ដើម្បីរកពន្លឺ ដូចមនុស្សខ្វាក់នេះ ខ្វាក់សិនដើម្បីមើលឃើញ។ ឲ្យយើងគិតពិចារណាថា **តើជីវិតរបស់ខ្ញុំទៅណា ធ្វើដូចម្ដេចដើម្បីឲ្យទៅមុខ?** នេះជាកម្លាំងមួយ ដើម្បីឲ្យខ្ញុំរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ យើងមានទស្សនៈ និងគោលបំណងរបស់យើង ក្រោយមកយើងមានសេចក្ដីស្រឡាញ់

ដែលយើងអនុវត្តតាម ពោរពេញដោយសេចក្តីសង្ឃឹម។ ពាក្យដែលប្រជាជននិយាយទៅកាន់អ្នកពិការភ្នែកនោះសំខាន់ណាស់ «**កុំអស់សង្ឃឹម!**»។ ជួនកាលយើងជាយុវជន យុវនារី យើងអស់សង្ឃឹមហើយ ដោយសារសង្គមរបស់យើងមិនរីកចម្រើនតាមគោលបំណង យើងអត់មានអ្វីដែលយើងចង់បាន។ យើងចង់បាននេះច្រើន តែអ្នកដឹកនាំមិនទាន់ទៅដល់សំណូមពររបស់យើង ដូច្នេះយើងចេញពីប្រទេសទៅធ្វើការនៅប្រទេសផ្សេង។ នេះគិតខុសហើយ ឲ្យនៅទីនេះរៀនសិន គិតសិនថា **តើខ្ញុំត្រូវធ្វើយ៉ាងម៉េចដើម្បីកសាងប្រទេសខ្ញុំ?** នេះជាតួនាទីរបស់ខ្ញុំ កុំទម្លាក់ឲ្យគេ។

ពិតមែនយើងមានគណៈកម្មការមេត្តាករុណា ប៉ុន្តែតួនាទីមេត្តាករុណាសម្រាប់យើងម្នាក់ៗ យើងមិនទម្លាក់លើគណៈកម្មការ យើងទាំងអស់គ្នាយើងមានភ្នែក ដើម្បីមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀតៗ។ គ្រីស្តបរិស័ទក៏ដូចគ្នាដែរ ជាពិសេសអ្នកចាស់ មិនអាចគិតថាពេលនេះខ្ញុំចូលនិវត្ត ដើម្បីទុកឲ្យគ្រីស្តបរិស័ទថ្មីធ្វើជំនួស អត់ទេ យើងត្រូវបន្តអស់ពីសមត្ថភាព ដើម្បីបង្ហាញថាខ្ញុំជាគ្រីស្តបរិស័ទ ខ្ញុំជាសាវ័ករបស់ព្រះយេស៊ូ និងខ្ញុំទទួលខុសត្រូវនៅក្នុងព្រះសហគមន៍ និងសង្គម តាមអ្វីដែលព្រះជាម្ចាស់ប្រទានឲ្យ នៅថ្ងៃដែលខ្ញុំបានទទួលអគ្គសញ្ញាជ្រមុជទឹក។ ដូច្នេះសម្រាប់ក្មេងៗក៏ដូចគ្នា សម្រាប់យុវជន យុវនារីក៏ដូចគ្នា សម្រាប់គ្រីស្តបរិស័ទទាំងអស់ក៏ដូចគ្នា យើងធ្វើយ៉ាងម៉េច ដើម្បីបំពេញគម្រោងការណ៍ដ៏អស្ចារ្យដែលព្រះជាម្ចាស់មានសម្រាប់ខ្ញុំផ្ទាល់។ យើងមិនទម្លាក់ឲ្យគេ យើងមិនទន្ទឹងរង់ចាំពីគេ យើងខិតខំធ្វើអស់ពីសមត្ថភាពរបស់យើង។ យើងអរព្រះគុណព្រះជាម្ចាស់ ដោយមិនភ្លេចនិយាយទៅព្រះយេស៊ូគ្រប់ពេលវេលាថា «**ឱព្រះយេស៊ូអើយ! សូមអាណិតមេត្តាទូលបង្គំផង!**»។ អាម៉ែន៕